**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ការប្រញាប់**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ: ៣១៧៥ កបទ.សអ/ច្បក២

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង**
**កុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស**

**កម្មវត្ថុ:** ការបន្តអនុវត្តវិធានការរឹតបន្តឹងការធ្វើដំណើរ និងការផ្អាកមិនឲ្យជនបរទេសមកពីប្រទេសបារាំង អាល្លឺម៉ង់ អ៊ីរ៉ង់ អ៊ីតាលី អេស្ប៉ាញ និងសហរដ្ឋអាមេរិក ចូលមកកម្ពុជា។

**យោង:**
- លិខិតលេខ ០៦៧ សខល ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល។
- លិខិតលេខ ២៥២១ ២៥៥១ និង២៧៩២ ចុះថ្ងៃ ១៤ ១៦ និង២៧ មីនា ២០២០ របស់ក្រសួង។

ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស ថា ក្រសួងសុខាភិបាលបានសម្រេចពន្យារសុពលភាពនៃវិធានការក្នុងការផ្អាកមិនឲ្យជនបរទេសដែលមកពីប្រទេស **បារាំង អាល្លឺម៉ង់ អ៊ីរ៉ង់ អ៊ីតាលី អេស្ប៉ាញ និងសហរដ្ឋអាមេរិក** ចូលមកព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះ ការផ្អាកគោលការណ៍លើកលែងទិដ្ឋាការ ការផ្តល់ទិដ្ឋាការទេសចរ ទិដ្ឋាការតាមប្រព័ន្ធអេឡិចត្រូនិច និងទិដ្ឋាការនៅពេលមកដល់ ក៏ដូចជាវិធានការសុខាភិបាលនានា រួមទាំងតម្រូវការវិញ្ញាបនប័ត្របញ្ជាក់សុខភាព និងឯកសារធានារ៉ាប់រងសុខភាព ត្រូវស្ថិតនៅជាធរមានបន្តទៅទៀត។

រាល់វិធានការរឹតបន្តឹងការធ្វើដំណើរទាំងអស់ខាងលើនេះ គឺមានលក្ខណៈជាបណ្តោះអាសន្ន និងត្រូវបន្តអនុវត្តរហូតដល់ស្ថានភាពជំងឺកូវីដ១៩ មានការធូរស្រាល ក្រោយពីមានការវាយតម្លៃរួមគ្នារវាងក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក។

សូម ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស អនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។✤

ថ្ងៃព្រហស្បតិ៍ ៩រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២០
**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ស៊ា កុសល**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh